**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ ០១.២១៣/០៧ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៧

# គ.ជ.ប មានកញ្ចប់ព័ត៌មានជា CD

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានផលិតកញ្ចប់ព័ត៌មានជា CD ដែលផ្ទុកឯកសារផ្លូវការទាំងអស់របស់ គ.ជ.ប ហើយឯកសារទាំងនេះ សម្រាប់ចែកជូនគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោត ។

ឯកសារផ្លូវការដែលផ្ទុកក្នុង CD រួមមាន ÷

- ច្បាប់បោះឆ្នោត
- បទបញ្ជា និងនីតិវិធី គ.ជ.ប
- បទសម្ភាសន៍ និងសន្ទរកថា របស់ ឯកឧត្តម ប្រធាន គ.ជ.ប
- សេចក្តីប្រកាសព័ត៌មានគ្រប់លេខទាំងអស់
- ព្រឹត្តិបត្រព័ត៌មាន គ.ជ.ប ដែលបានចេញផ្សាយរួច
- លិខិតចេញទៅស្ថាប័នពាក់ព័ន្ធជាដើម ។ល។

លោក ខន កែវមនោ អនុប្រធាននាយកដ្ឋានទទួលបន្ទុកផ្នែកព័ត៌មានសាធារណៈ បានមានប្រសាសន៍ថា នេះជាគំនិតផ្តួចផ្តើមថ្មីមួយទៀត ដោយមើលឃើញថា បច្ចុប្បន្នប្រទេសកម្ពុជាកំពុងរីកចំរើនផ្នែកព័ត៌មានវិទ្យា ហេតុនេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប ផលិតកញ្ចប់ព័ត៌មានជា CD នេះឡើង ដើម្បីបង្កលក្ខណៈងាយស្រួលដល់ភាគីពាក់ព័ន្ធនឹងការបោះឆ្នោតទាំងអស់ដែលចង់ដឹង និងតាមដានព័ត៌មានអំពីការបោះឆ្នោត ។ លោកបន្តថា កញ្ចប់ព័ត៌មានជា CD Data នេះ មានផលប្រយោជន៍ ២យ៉ាង : ទី១ ងាយស្រួលដាក់តាមខ្លួន និងរក្សាទុក បើចងក្រងជាក្រដាសអាចមានទំហំធំ គឺច្រើនជាង ១០០០ទំព័រ ។ ទី២ ការចំណាយអស់តិចជាងការផលិតជាសៀវភៅ ។ លោកបានបន្តឱ្យដឹងទៀតថា នៅមុនថ្ងៃបោះឆ្នោត អគ្គលេខាធិការដ្ឋាន គ.ជ.ប នឹងចេញ CD Data នេះលេខ ២ បន្តទៀត ។

ទោះជាយ៉ាងណាក៏ដោយ លោកមានប្រសាសន៍ថា CD ដែលផលិតនេះមិនមានចំនួនច្រើនទេ អគ្គលេខាធិការដ្ឋាន គ.ជ.ប អាចចែកបាន ១ CD ប៉ុណ្ណោះ ក្នុង១គណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ ទី២ ឆ្នាំ២០០៧ នេះ ហើយអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតអាចទទួលបាន ១ CD ដែរក្នុងមួយស្ថាប័ន ។